# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលបង្កើតផ្លាកសញ្ញាមួយចំនួនបំពេញបន្ថែមលើមាត្រា ៦ នៃអនុក្រឹត្យលេខ ០៧ អនក្រ. បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋានផ្លាកសញ្ញានិងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ០៧ / អនក្រ.បក / ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១** : ត្រូវបានបង្កើតផ្លាកសញ្ញាមួយចំនួនបំពេញបន្ថែមមាត្រា ៦ នៃអនុក្រឹត្យលេខ ០៧ /អនក្រ.បក/ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ ឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ ដូចមានខាងក្រោម ÷

**ក- <u>សញ្ញាអគ្គបញ្ជាការ :</u>**

សញ្ញាអគ្គបញ្ជាការមាន ២ ប្រភេទ ដែលមានរូបភាព និងខ្នាត ដូចក្នុងឧបសម្ព័ន្ធភ្ជាប់ត្រូវបាន កំណត់ដូចតទៅ ÷

**ក១- <u>សញ្ញាអគ្គបញ្ជាការ ប្រភេទទី ១ :</u>**

មានរាងពងក្រពើ គ្មានហ៊ុងនៅពីក្រោយ ដែលមានកំពស់ប្រវែង ៣,៨ សម ទទឹងប្រវែង ៤,៦ សម និងមានកំពស់ ០,៣ សម ។ នៅជុំវិញមានរចនាលំអដោយ គូរស្រូវពីរ គោងរាងស្នែងក្របី ដែលតំណាង អោយប្រជារាស្ត្រ ។ នៅចំកណ្តាលមានផ្កាយពណ៌មាស និងខៀវ មានជ្រុងប្រាំបី ដែលតំណាងអោយ ឫទ្ធិបារមី ទិសទាំងប្រាំបី ។ នៅចំកណ្តាលតួផ្កាយ មានផ្ទុំប្រសព្វដោយរូបលំពែងត្រីសូល្យ ស្លាបសត្វហង្ស និងយុថ្កា ពណ៌មាស ដែលតំណាងអោយកងទ័ពទាំងបីប្រភេទ ។

សញ្ញានេះធ្វើអំពីលោហធាតុ សំរាប់ពាក់នៅលើគំរបហោប៉ៅស្តាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋាន លេខ ២- ៣- ៤ ប្រើប្រាស់នៅលើក្បាលលិខិត និងធ្វើជាសញ្ញាសំគាល់របស់អគ្គបញ្ជាការដ្ឋាន ។

**ក២- <u>សញ្ញាអគ្គបញ្ជាការ ប្រភេទ ២ :</u>**

មានរាងជាខែលមានហ៊ុងពណ៌ទង់ជាតិបញ្ចិត មានកំពង់ប្រវែង ១០ សម និងទទឹងប្រវែង ៨ សម ។ នៅលើផ្ទៃខែល មានរូបដូចសញ្ញាអគ្គបញ្ជាការទី ១ មានអក្សរ ខ.ភ.ម នៅពីលើរូប និងអក្សរ អគ្គបញ្ជាការ នៅពីក្រោមរូប ។

សញ្ញានេះ ប៉ាក់ ឬបោះពុម្ពនៅលើក្រណាត់ សំរាប់ពាក់នៅដើមដៃឆ្វេង នៃឯកសណ្ឋាន ។

សញ្ញាអគ្គបញ្ជាការប្រភេទទី ១ និងទី ២ ប្រើសំរាប់យោធិន ដែលបំពេញការងារនៅអគ្គបញ្ជាការដ្ឋាន និងស្ថាប័នចំណុះអគ្គបញ្ជាការ ( មានការកំណត់ដោយអគ្គបញ្ជាការ ) ។

**ខ- <u>សញ្ញាកងទ័ពជើងគោក :</u>**

សញ្ញាកងទ័ពជើងគោកមាន ២ ប្រភេទ ដែលមានរូបភាព និងខ្នាត ដូចក្នុងឧបសម្ព័ន្ធភ្ជាប់ត្រូវបាន កំណត់ ដូចតទៅ ÷

**ខ១- <u>សញ្ញាកងទ័ពជើងគោក ប្រភេទទី ១ :</u>**

មានរាងពងក្រពើ និងពណ៌ទឹកមាស ដែលមានកំពស់ប្រវែង ៣,៨ សម ទទឹងប្រវែង ៥,១ សម និង កំពស់ប្រវែង ០,៣ សម ។ នៅខាងក្រោមចំកណ្តាល មានក្បាច់ដកចន្ទន៍ និងក្បាច់ភ្ញីទេសពីរខ្សែរគោង រាងស្នែងក្របី ។ ចំកណ្តាលមានទង់ជាតិ ដែលមានរាងជាខែល ។ នៅចំកណ្តាល មានរូបប្រាសាទអង្គរ រូប លំពែងត្រីសូល្យ ដាវ និងកាំភ្លើងពណ៌ស ដាក់ខ្វែងគ្នាតំណាងអោយទ័ពជើងគោក ។

សញ្ញានេះធ្វើអំពី លោហធាតុ សំរាប់ពាក់នៅលើគំរបហោប៉ៅស្តាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋាន និងប្រើប្រាស់ជាសញ្ញារបស់កងទ័ពជើងគោក ។

**១២- សញ្ញាកងទ័ពជើងគោក ប្រភេទទី ២ :**

មានរាងពងក្រពើ មានពណ៌ខៀវខ្ចី ដែលមានកំពស់ប្រវែង ៣,៨ សម និងទទឹងប្រវែង ១,៥ សម ។ នៅចំកណ្ដាល មានរូបសញ្ញាដូចកងទ័ពជើងគោកប្រភេទទី ១ ។

សញ្ញានេះប៉ាក់ ឬបោះពុម្ពលើក្រណាត់ សំរាប់ពាក់នៅដើមដៃឆ្វេង នៃឯកសណ្ឋានសញ្ញាប្រភេទទី ១ និងទី ២ ប្រើចំពោះយោធិនដែលបំពេញការងារ នៅបញ្ជាការដ្ឋាន និងកងឯកភាពចំណុះកងទ័ពជើងគោក ។

**គ- សញ្ញាកងទ័ពជើងទឹក :**

សញ្ញាកងទ័ពជើងទឹកមាន ២ ប្រភេទ ដែលមានរូបភាព និងខ្នាត ដូចក្នុងឧបសម្ព័ន្ធភ្ជាប់ត្រូវបានកំណត់ដូចតទៅ ÷

**គ១- សញ្ញាកងទ័ពជើងទឹក ប្រភេទទី ១ :**

មានរាងជាទឹករលកពីរជាន់ តំណាងផ្ទៃសមុទ្រ ដែលមានកំពស់ប្រវែង ២,៩ សម និង ៧ សម នៅចំកណ្ដាលទឹករលក មានរូបយុទ្ធថ្កា ចង្កូតនាវា និងរូបក្បាលនាគពណ៌ស ដែលតំណាងអោយកងទ័ពជើងទឹក ។ សញ្ញានេះធ្វើអំពីលោហធាតុពណ៌មាស សំរាប់ពាក់នៅតំបន់ហោប៉ៅស្ដាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋានរបស់ទាហាន ដែលបំពេញការងារនៅបញ្ជាការដ្ឋាន កងឯកភាពចំណុះ លើក្បាលលិខិតប្រើប្រាស់ជាផ្លូវការ និងបញ្ជាការដ្ឋានកងទ័ពជើងទឹក ។

**គ២- សញ្ញាកងទ័ពជើងទឹកប្រភេទទី ២ :**

មានរង្វង់ពីរជាន់ ដែលមានបន្ទាត់ផ្ចិត ៨ សម រង្វង់ខាងក្រៅពណ៌ស ផ្នែកខាងលើ មានចារអក្សរកងយោធពលខេមរភូមិន្ទ ផ្នែកខាងក្រោម មានចារអក្សរកងទ័ពជើងទឹក គោងតាមរាងរង្វង់ និងរូបផ្កាចន្ទន៍ពណ៌ស ចែករង្វង់ជាពីរផ្នែកស្មើគ្នា ។ រង្វង់ខាងក្នុងពណ៌ខៀវខ្ចីនៅចំកណ្ដាល មានរូបយុទ្ធថ្កាក្បាលនាគ និងរូបមុដរាជ្យ នៅពីក្រោមរូបមានគូរស្រូវពីរ គួរព័ទ្ធជារង្វង់ស្ទែងក្របី ។

សញ្ញានេះ ប៉ាក់ឬបោះពុម្ពលើក្រណាត់សំរាប់ពាក់លើដើមដៃឆ្វេង នៃឯកសណ្ឋាន ប្រើសំរាប់យោធិនដែលបំពេញការងារ នៅតាមស្ថាប័ន និងកងឯកភាពចំណុះបញ្ជាការដ្ឋានកងទ័ពជើងទឹក ។

**ឃ- សញ្ញាកងទ័ពជើងអាកាស :**

សញ្ញាកងទ័ពជើងអាកាសមាន ១ ប្រភេទ ដែលមានរូបភាព និងខ្នាត ដូចក្នុងឧបសម្ព័ន្ធភ្ជាប់ត្រូវបានកំណត់ដូចតទៅ ÷

**ឃ១- សញ្ញាកងទ័ពជើងអាកាស ប្រភេទទី ១ :**

រូបស្លាបសត្វហង្សដែលជានិមិត្តសញ្ញាកងទ័ពជើងអាកាស ដែលមានកំពស់ប្រវែង ៣ សម និងទទឹង ៨,៣ សម ។ នៅចំកណ្ដាលស្លាបសត្វហង្ស ផ្នែកខាងក្រោម មានទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជារាងខែលមានពណ៌ទឹកមាស ។

សញ្ញានេះធ្វើអំពីលោហធាតុពណ៌មាស សំរាប់ពាក់នៅតំបន់ហោប៉ៅស្តាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋានលេខ ២-៣-៤ នៅលើក្បាលលិខិតជាផ្លូវការ និងដាក់នៅបញ្ជាការដ្ឋានកងទ័ពជើងអាកាស ។

**ខ-** <u>**រូបសញ្ញា ក្រសួងការពារជាតិ**</u> : តាមសេចក្តីសំរេចលេខ ១៦ / សសរ / ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០ ត្រូវពាក់នៅលើហោប៉ៅអាវខាងឆ្វេង ។

**មាត្រា ២** : ក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ មានសិទ្ធិចេញសេចក្តីសំរេចក្នុងការបង្កើតសញ្ញាសំគាល់អោយបណ្តាស្ថាប័ន និងកងឯកភាពចំណុះ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០១*

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

## ផ្លាកសញ្ញាសំគាល់ក្រសួងការពារជាតិ



## ផ្លាកសញ្ញាសំគាល់អគ្គបញ្ជាការ



## ផ្លាកសញ្ញាសំគាល់ទ័ពជើងគោក



## ផ្លាកសញ្ញាសំគាល់ទ័ពជើងទឹក



## ផ្លាកសញ្ញាសំគាល់ទ័ពជើងអាកាស

